សូមប្រឹក្សាពិគ្រោះ ពេលណាក៏បាន
ថ្ងៃទទួល: ច័ន្ទ ដល់ សុក្រ
ម៉ោង: 9:00 ដល់ 17:00

ប្រឹក្សាពិគ្រោះដោយឥតគិតថ្លៃ/រក្សាការសំងាត់ដាច់ខាត

លេខទូរសព្ទផ្ទាល់ : 090-4517-5820




# តើអ្នកព្រួយខ្វល់តែម្នាក់ឯងឬទេ?




ប្រសិនបើអ្នកកំពុងមានបញ្ហាក្នុងជីវិតរបស់អ្នកដោយសារបញ្ហាផ្សេងៗដូចជាបំណុល ភាពអត់ការងារធ្វើ ជំងឺ ទំនាក់ទំនងមនុស្ស ភាពឯកា ឬអនាគត សូមកុំព្រួយខ្វល់តែម្នាក់ឯង។
យើងគិតជាមួយគ្នា ហើយជួយរកដំណោះស្រាយ។
សូមបញ្ចេញភាពក្លាហាន ហើយប្រឹក្សាពិគ្រោះ។

**ក្រុមប្រឹក្សាសង្កាត់Minamioguni ផ្នែកសុខុមាលភាពសង្គម**
លេខទូរសព្ទ: 0967-42-1501
លេខទូរសព្ទផ្ទាល់: 090-4517-5820

(យើងក៏ឆ្លើយតបចំពោះការប្រឹក្សាពិគ្រោះតាម(LINE/ពីចម្ងាយ(រីម៉ូត)ផងដែរ។)

ទម្រង់ទទួលប្រឹក្សាពិគ្រោះ QRកូដ

ទំនាក់ទំនង/អាសយដ្ឋាន QRកូដ

ចុះបញ្ជី LINE QRកូដ



# តើអ្នកកំពុងមានបញ្ហាដូនេះឬទេ?

## ការសម្ងាត់ដាច់ខាត



### ការចំណាយលើជីវភាព

- ចង់ដោះស្រាយបំណុល
- គ្មានលទ្ធភាពបង់ប្រាក់ពន្ធនិងថ្លៃសេវាសាធារណៈ
- មិនអាចគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ និងជីវភាពលំបាក
- បារម្ភថាអាចរស់នៅដោយតែប្រាក់សោធនឬទេ

យើងនឹងផ្ដល់យោបល់អំពីរបៀបកសាងសេដ្ឋកិច្ចគ្រួសារ ឡើងវិញ
និងបង្កើតផែនការគាំទ្រដែលសមស្របនឹងស្ថានភាពរបស់អ្នក
ព្រមទាំងសម្របសម្រួលប្រាក់កម្ចី
ដើម្បីឱ្យអ្នកអាចគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារដោយខ្លួនឯង។



### ការងារ

- ពិបាករកការងារបានធ្វើ
- ចំណូលគ្មានស្ថេរភាព ដោយសារការងារមិនបន្ត
- ចង់ចាប់ផ្តើមការងារតែខ្លាចថាអាចធ្វើការបានឬអត់។

យើងផ្តល់ការគាំទ្រដល់អ្នកដើម្បីទទួលបានការងារ។
យើងផ្តល់ឱកាសបណ្តុះបណ្តាល
និងបទពិសោធន៍ការងារដល់អ្នកដែលព្រួយបារម្ភពីការចាប់ផ្តើមធ្វើការភ្លាមៗ
ដូចជាអ្នកដែលព្រួយបារម្ភអំពីទំនាក់ទំនងរបស់ពួកគេជាមួយសង្គម
ឬអ្នកដែលមិនមានទំនាក់ទំនងល្អជាមួយអ្នកដទៃ។



### កូននិងគ្រួសារ

- ព្រួយបារម្ភពីថ្លៃសិក្សានិងការសិក្សារបស់កូន
- មានសមាជិកគ្រួសារដែលនៅតែក្នុងផ្ទះជាដើម

យើងគាំទ្រអនាគតរបស់កុមារ និងយុវជន។
យើងផ្តល់ការគាំពារចាំបាច់ដល់កុមារ យុវជន
និងអាណាព្យាបាលរបស់ពួកគេទាក់ទងនឹងការផ្គត់ផ្គង់ការសិក្សា ការបង្កើតកន្លែងស្នាក់នៅ
ការបន្តសិក្សា
ងការការពារទប់ស្កាត់ការបោះបង់សិក្សារបស់កុមារ។



### ការស្នាក់នៅ

- ត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារ និងគ្មានកន្លែងស្នាក់នៅ
- គ្មានលទ្ធភាពបង់ថ្លៃឈ្នួលផ្ទះ ហើយត្រូវចេញពីផ្ទះ

យើងផ្តល់ការគាំទ្រដើម្បីរក្សាបានលំនៅឋាន
និងកន្លែងស្នាក់នៅបណ្តោះអាសន្ន
ចំពោះអ្នកដែលបានបាត់បង់
ឬអ្នកដែលអាចនឹងបាត់បង់ផ្ទះស្នាក់នៅ
ដោយសារការបាត់បង់ការងារជាដើម។

**ដើម្បីសំដៅ “បង្កើតសង្គមដែលគ្មានអ្នកដែលត្រូវបានទុកចោល”**

**សម្រាប់អ្នកមានការលំបាក ឬអ្នកមានកង្វល់ដែលនៅជុំវិញអ្នក**

**សូមប្រឹក្សាពិគ្រោះ។ យើងរក្សាការសំងាត់។**